# National Foresight and Theory of Change Workshop

# បទពិសោធន៍ និងស្ថានភាពទីផ្សារបន្លែសុវត្ថិភាព

Prepared by
Name: Bun Sieng
Date : 18 Oct 2022

Funded by the European Union and the French Development Agency

# សេចក្តីណែនាំសង្ខេប

- ✓ ចាប់ដំណើរការនៅឆ្នាំ2012 (10ឆ្នាំ) ផ្តោតលើបន្លែសុវត្ថិភាព (សរីរាង្គ និងអនុវត្តកសិកម្មល្អ)

- ✓ បានចុះកិច្ចសន្យាទិញលក់ជាមួយកសិករ ជិត300គ្រួសារ ជាង10ខេត្ត

- ✓ ភូមិកសិកម្មធម្មជាតិមានទិសដៅរួមគ្នាជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការពង្រីកទីផ្សារបន្លែសុវត្ថិភាព និងជីវភាពកសិករក្នុងស្រុក





# ការនាំបន្លែសុវត្ថិភាពទៅកាន់ទីផ្សារ

- មុននឹងជ្រើសរើសកសិករ យើងត្រូវពិនិត្យមើលទីតាំងជាមុន
- ធ្វើការបណ្តុះបណ្តាលកសិករបន្ថែម
- សហការជាមួយមន្ទីរកសិកម្ម និងអគ្គនាយកដ្ឋានកសិកម្ម និងគម្រោងនានាក្នុងការជម្រុញ វិញ្ញាបនបត្រសុវត្ថិភាព (សរីរាង្គ និងCamGAP)
- មានកិច្ចសន្យាទិញលក់ជាមួយកសិករ
- ផ្តល់នូវតម្លៃសមរម្យសម្រាប់កសិករ និងធានាទិញពេញមួយឆ្នាំ
- លើកទឹកចិត្តទីផ្សារនិងអ្នកហូបបានជួបកសិករផ្ទាល់ ដើម្បីយល់ពីគ្នាទៅវិញទៅមកកាន់តែច្បាស់។
- ធានាគុណភាពពិតប្រាកដដល់អ្នកហូប






# ការផ្លាស់ប្តូរក្នុងការជម្រុញបន្លែសុវត្ថិភាព

| 10 ឆ្នាំមុន | បច្ចុប្បន្ន |
|---|---|
| 1-មានកសិករជាច្រើនមិនជឿថាអាចផលិតបន្លែសុវត្ថិភាពបាន (ទាំងសរិរាង្គ និងCamGAP) | 1-អោយតែមានកិច្ចសន្យាទិញលក់ កសិករអាចផលិតអោយបាន |
| 2-ដាំបន្លែវិលជុំ ប្រមូលផលរាល់ថ្ងៃតិចៗ មិនចំនេញទេ | 2-កសិករកាន់តែពង្រីកផ្ទៃដីដាំដុះបន្លែសុវត្ថិភាពបន្ថែម ព្រោះគាត់ពិតជាអាចរកប្រាក់ចំនេញបានច្រើនជាងដាំបន្លែខាងក្រៅ |
| 3-គុណភាពសុវត្ថិភាព ប៉ុន្តែមិនទាន់មានការព បញ្ជាក់គុណភាព | 3-មានការបញ្ជាក់គុណភាពត្រឹមត្រូវ ទាំងបន្លែសរីរាង្គ និងបន្លែអនុវត្តកសិកម្មល្អ |
| 4-ទីផ្សារមិនយល់អំពីស្លាកសញ្ញាសុវត្ថិភាព និងការបញ្ជាក់គុណភាព | 4-ទីផ្សារជាច្រើនមានការយល់ដឹងអំពីការបញ្ជាក់គុណភាព និងទាមទាររកស្លាកបញ្ជាក់គុណភាព |
| 5-មានទីផ្សារតិចតួចលក់បន្លែសុវត្ថិភាព | 5-ទីផ្សារបន្លែសុវត្ថិភាពរីកច្រើនកន្លែង កាន់តែងាយស្រួលក្នុងការស្វែងរក |
| 6-គម្រោងជាច្រើនផ្តើតលើការផលិត | 6-មានគម្រោងជាច្រើនផ្តោតលើការជម្រុញទីផ្សារបន្លែសុវត្ថិភាព |





# ការពង្រីកទីផ្សារបន្លែសុវត្ថិភាព

ក្នុងការពង្រីកបន្លែសុវត្ថិភាព ទីផ្សារមានតម្រូវការមួយចំនួនដូចខាងក្រោម៖

- កសិករមានភាពស្មោះត្រង់
- កសិករប្រមូលផ្តុំគ្នា នៅជិតៗគ្នាដើម្បីងាយស្រួលតាមដាន និងដឹកជញ្ជូន
- អាចដាំបាននូវប្រភេទបន្លែដែលទីផ្សារត្រូវការ
- អនុវត្តតាមគោលការណ៍បន្លែសុវត្ថិភាព និងទទួលបានវិញ្ញាបនបត្រ



# ហេតុអ្វីកសិករខ្លះផ្លាស់ប្តូរទៅដាំបន្លែសុវត្ថិភាព?

មានកសិករកាន់តែច្រើនឡើងបានផ្លាស់ប្តូរពី កសិកម្មគីមី ទៅជាកសិកម្មអេកូឡូស៊ី ដោយសារគាត់មានការយល់ដឹងអំពី៖



- ✓ សុខភាពគាត់និងក្រុមគ្រួសារគាត់
- ✓ សុខភាពអ្នកជិតខាង អ្នកហូប និងបរិស្ថាន
- ✓ លក់បានថ្លៃជាងបន្លែខាងក្រៅ និងចំនេញជាង
- ✓ មាននិរន្តភាពទីផ្សារនៅពេលគាត់មានកិច្ចសន្យាទិញលក់ជាមួយទីផ្សារ



# ឱកាស

- ផ្សារបន្លែសុវត្ថិភាពបើកថ្មីកាន់តែច្រើនឡើង ស្របពេលប្រជាជនមានការយល់ដឹងច្រើនអំពីការហូបបន្លែសុវត្ថិភាពដើម្បីសុខភាព
- ទាំងរដ្ឋ គម្រោងនានា និងវិស័យឯកជន កំពុងសហការគ្នាដើម្បីជម្រុញទិផ្សារបន្លែសុវត្ថិភាពអោយកាន់តែរីកចម្រើនថែមទៀត
- មានទីផ្សារជាច្រើនបានចុះកិច្ចសន្យាទិញលក់ជាមួយកសិករ
- ស្ថាបនជាច្រើនកំពុងជម្រុញស្លាកសញ្ញាបញ្ជាក់គុណភាព ដែលអាចអោយអ្នកហូបមានទំនុកចិត្ត កាន់តែគាំទ្រច្រើនឡើង
- តម្រូវការបន្លែសុវត្ថិភាពមានការកើនឡើងយ៉ាងខ្លាំងនិងមិនទាន់គ្រប់តម្រូវការ

# បញ្ហាប្រឈម

- ចំនួនកសិករដែលបានបញ្ជាក់គុណភាពនៅមានកំរិត មិនទាន់គ្រប់គ្រាន់ យើងមិនអាចបិតស្លាកសញ្ញាបានគ្រប់ផលិតផល

- ចំនួនផ្ទះសំណាញ់ដាំបន្លែកើនឡើងច្រើន តែនៅតែមិនទាន់គ្រប់គ្រាន់ គ្រប់តម្រូវការទីផ្សារ

- ការយល់ដឹងរបស់កសិករជាច្រើនលើវិធានការការពារដំណាំនៅមានកំរិត ពួកគាត់ភាគច្រើនផ្តោតលើវិធានការព្យាបាលធ្វើអោយដំណាំពិបាក សង្គ្រោះនៅពេលមានជម្ងឺ ឬសត្វល្អិតផ្ទុះឡើង។

- មានបន្លែជាច្រើនដាក់ស្លាកសុវត្ថិភាពនៅលើទីផ្សារ ប៉ុន្តែមិនមានប្រភពច្បាស់លាស់

# ក្ដីសង្ឃឹមក្នុង10ឆ្នាំទៅមុខទៀត

- សង្ឃឹមថាប្រទេសកម្ពុជាយើងនឹងមានផ្សារលក់ដុំបន្លែសុវត្ថិភាពធំមួយ ដែលបន្លែគ្រប់ខេត្ត យកមកលក់នៅមួយកន្លែង (គម្រោងដី20ហាត)

- ងាយស្រួលក្នុងការបែងចែកបន្លែពីគ្រប់តំបន់ ត្រឹតគុណភាព និងចំនេញពេលវេលា ដល់ទីផ្សារ

- អាចធ្វើការនាំចេញ



# សំណូមពរ

តើកសិករអាចផលិតបន្លែសុវត្ថិភាពដោយមានវិញ្ញាបនបត្រសរីរាង្គ ឬអនុវត្តកសិកម្មល្អបានច្រើនជាមុនបានទេ? តើកត្តាអ្វីខ្លះដែលមិនអាចទទួលបានវិញ្ញាបនបត្រទាំងនោះ?

ស្នើសុំមានការសម្របសម្រួលផែនការដាំដុះបន្លែសុវត្ថិភាពថ្នាក់ជាតិ ដើម្បីកាត់បន្ថយបន្លែដាំដើសតម្រូវការច្រើនពេក ជាពិសេសនារដូវរំហើយ។

ស្នើសុំមានការចុះត្រួតពិនិត្យគុណភាពនៅលើទីផ្សារបានកាន់តែច្រើន

# សូមអរគុណ! THANK YOU

The project is funded by

ASSET Partners